វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០៤ ខែមករា ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- រោងចក្រផលិតថាមពលពីព្រះអាទិត្យ(សូឡា)នៅក្នុងប្រទេសកម្ពុជានឹងបន្ថែមការផ្គត់ផ្គង់អគ្គិសនីក្នុងស្រុក នៅមុនចុងឆ្នាំ២០១៩
- ប្រទេសចិនកាត់បន្ថយកូតានាំចូលប្រេងឆៅ នៅដើមឆ្នាំ២០១៩
- ការនាំចេញប្រេងឆៅរបស់អាមេរិកទៅអឺរ៉ុប បានធ្លាក់ចុះទាបបំផុតក្នុងរយៈពេល១១ខែ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### រោងចក្រផលិតថាមពលពីព្រះអាទិត្យ នៅក្នុងប្រទេសកម្ពុជា នឹងបន្ថែមការផ្គត់ផ្គង់អគ្គិសនីក្នុងស្រុក នៅមុនចុងឆ្នាំ២០១៩

ក្រុមហ៊ុន Jinko Solar Holding Co., Ltd ដែលជាក្រុមហ៊ុនផលិតបន្ទះថាមពលពីពន្លឺព្រះអាទិត្យ(សូឡា)ដ៏ធំជាងគេក្នុងពិភពលោក កំពុងតែដំណើរការសាងសង់រោងចក្រផលិតថាមពលពីពន្លឺព្រះអាទិត្យដែលមានអានុភាព៦០មេហ្គាវ៉ាត់ និងមានតម្លៃជាង៥៨លានដុល្លារអាមេរិក នៅក្នុងខេត្តកំពង់ស្ពឺ។ រោងចក្រនេះនឹងបំពាក់ផ្ទាំងសូឡាចំនួន២០០ ០០០បន្ទះ គិតចាប់ពីដើមឆ្នាំ២០១៩ ហើយប្រតិបត្តិការនឹងចាប់ផ្តើមមុនចុងឆ្នាំនេះ។

រោងចក្រផលិតថាមពលពីពន្លឺព្រះអាទិត្យនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញនូវកំណើនតម្រូវការអគ្គិសនីនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បាននាំចូលអគ្គិសនី ចំនួន ៤៤២,៥០មេហ្គាវ៉ាត់ នៅក្នុងឆ្នាំ២០១៨។ លោក វ៉ី សំណាង អភិបាលខេត្តកំពង់ស្ពឺ បានថ្លែងថា: គម្រោងនេះនឹងចូលរួមចំណែកក្នុងការជម្រុញកំណើនសេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន។

### តារាងប្រចាំសប្តាហ៍៖ ពាណិជ្ជកម្មអន្តរជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ត្រីមាសទី២ ឆ្នាំ២០១៨

ការនាំចូលរបស់កម្ពុជាបានកើនឡើងដល់ ១៨ ៣២៩ប៊ីលានរៀល ក្នុងត្រីមាសទី២ នៅឆ្នាំ២០១៨ ពោលគឺកើនឡើង ៦,១% ធៀបទៅនឹងត្រីមាសមុន។ ចំណែកសំខាន់ៗដែលធ្វើអោយមានការកើនឡើងនេះគឺការនាំចូលវត្ថុធាតុដើមសំលៀកបំពាក់ ដែលកើនឡើង ៩៤៥ប៊ីលានរៀល ស្មើនឹង ២៥,៣% និងម្ហូបអាហារ និងភេសជ្ជៈ កើនឡើង ៤២ប៊ីលានរៀល ស្មើនឹង ៥,២%។

ក្នុងកំឡុងពេលដូចគ្នានេះដែរ ការនាំចេញមានតម្លៃស្មើនឹង ១២ ៦៥១ប៊ីលានរៀល ក្នុងត្រីមាសទី២ គឺកើនឡើង ៨,៩%។ ការកើន

ឡើងនេះ ត្រូវបានរួមចំណែកច្រើនជាងគេដោយការនាំចេញសម្លៀកបំពាក់ និងស្បែកជើង។

### ការនាំចូល និងនាំចេញ ពីឆ្នាំ២០១៦ ដល់ត្រីមាសទី២ឆ្នាំ២០១៨ (គិតជាប៊ីលានរៀល)




ប្រភព៖ ធនាគាជាតិនៃកម្ពុជា ឆ្នាំ២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ចិនកាត់បន្ថយកូតានាំចូលប្រេងឆៅ នៅដើមឆ្នាំ២០១៩

ក្រសួងពាណិជ្ជកម្មរបស់ប្រទេសចិន បានចេញនូវរបាយការណ៍អំពីកូតានាំចូលប្រេងឆៅដំបូងរបស់ខ្លួន សម្រាប់ឆ្នាំ២០១៩ កាលពីថ្ងៃទី០២ ខែមករា ដោយកាត់បន្ថយបរិមាណមកត្រឹម ៨៩,៨៤លានតោន ធៀបទៅនឹងបរិមាណឆ្នាំមុនដែលមានចំនួន ១២១,៣២លានតោន។

ការធ្លាក់ចុះនេះបង្ហាញថា តម្រូវការប្រេងឆៅអាចនឹងមានកំណើនយឺត សម្រាប់ឆមាសដំបូងនៃឆ្នាំ២០១៩។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកជំនាញនៅក្នុងទីផ្សារ ចម្រាញ់ប្រេងរបស់ចិនរំពឹងថា បរិមាណកូតានាំចូលប្រេងឆៅនឹងកើនឡើងវិញក្នុងដំណាក់កាលទី២នៅក្នុងឆ្នាំនេះ ដែលជាធម្មតាគឺនៅក្នុងខែកញ្ញា នេះបើយោងតាមសារព័ត៌មានអន្តរជាតិ Reuters។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ការនាំចេញប្រេងឆៅរបស់សហរដ្ឋអាមេរិកទៅអឺរ៉ុប បានធ្លាក់ចុះទាបបំផុត ក្នុងរយៈពេល ១១ខែ

ការនាំចេញប្រេងឆៅពីរដ្ឋ Texas និងរដ្ឋLouisiana ទៅកាន់អឺរ៉ុបបានធ្លាក់ចុះ ពីចំនួន៨០៤ ០០០បារ៉ែល ក្នុងមួយថ្ងៃ នៅខែវិច្ឆិកាមកត្រឹម២៩៨ ០០០បារ៉ែល ក្នុងមួយថ្ងៃ នៅខែធ្នូ ដែលនេះគឺជាកម្រិតទាបបំផុតនៃការនាំចេញ គិតចាប់ពីខែមករា ឆ្នាំ២០១៨ បើយោងតាមសារព័ត៌មានអន្តរជាតិ Reuters។

ការធ្លាក់ចុះនៃតម្រូវការប្រេងឆៅរបស់អាមេរិក គឺដោយសារតែការបញ្ចុះតម្លៃមានការធ្លាក់ចុះ ធៀបទៅនឹងប្រេងប្រភេទBrent និងការកើនឡើងនូវថ្លៃដឹកជញ្ជូន ក៏ដូចជាការកើនឡើងតម្លៃខ្ពស់ សម្រាប់ប្រភេទប្រេងដែលនៅតំបន់ឈូងសមុទ្រអាមេរិក (U.S. Gulf Coast)។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ អតិផរណានៅអាមេរិក និងចិន និងភាពអត់ការងារធ្វើនៅប្រទេសកូរ៉េខាងត្បូង។ ព្រឹត្តិការណ៍សំខាន់ៗ រួមមាន៖ កិច្ចពិភាក្សាពាណិជ្ជកម្មរវាង អាមេរិក និងចិន ដែលនឹងចាប់ផ្តើមនៅថ្ងៃច័ន្ទ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី០៧ ខែមករា

- ទំនុកចិត្តអ្នកប្រើប្រាស់នៅ ឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ
- អត្រាដោះដូរទុនបម្រុងនៅ កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- ជំនួបពិភាក្សាពាណិជ្ជកម្ម រវាង អាមេរិក និងចិន
- សមតុល្យពាណិជ្ជកម្មនៅ តៃវ៉ាន់ សម្រាប់ខែធ្នូ

ថ្ងៃអង្គារ ទី០៨ ខែមករា

- ទំនុកចិត្តអ្នកប្រើប្រាស់នៅជប៉ុន សម្រាប់ខែធ្នូ

- អត្រាអតិផរណានៅតៃវ៉ាន់ សម្រាប់ខែធ្នូ
- គណនីចរន្តកូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- ទុនបម្រុងអន្តរជាតិនៅឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ

ថ្ងៃពុធ ទី០៩ ខែមករា

- ឥណទានអ្នកប្រើប្រាស់នៅអាមេរិក សម្រាប់ខែវិច្ឆិកា
- អត្រាភាពអត់ការងារធ្វើនៅកូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- ថ្លៃលក់រាយនៅហ្វីលីពីន សម្រាប់ខែវិច្ឆិកា
- ការលក់ឡាននៅឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ
- ការលក់រាយនៅឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ
- អត្រាភាពអត់ការងារធ្វើនៅតំបន់អឺរ៉ុប សម្រាប់ខែវិច្ឆិកា

ថ្ងៃព្រហស្បតិ៍ ទី១០ ខែមករា

- សមតុល្យពាណិជ្ជកម្មហ្វីលីពីន សម្រាប់ខែវិច្ឆិកា
- អត្រាអតិផរណាចិន សម្រាប់ខែធ្នូ
- ការវិនិយោគដោយផ្ទាល់ពីបរទេសហ្វីលីពីន  សម្រាប់ខែធ្នូ
- ការប្រកាសដំបូងពីភាពអត់ការងារ នៅអាមេរិក សម្រាប់ថ្ងៃទី០៦ ខែមករា

ថ្ងៃសុក្រ ទី១១ ខែមករា

- ផលិតកម្មឧស្សាហកម្មម៉ាឡេស៊ី សម្រាប់ខែវិច្ឆិកា
- ផ.ស.ស នៅចក្រភពអង់គ្លេស សម្រាប់ខែវិច្ឆិកា
- អត្រាអតិផរណានៅអាមេរិក សម្រាប់ខែធ្នូ
- ការលក់រាយនៅសឹង្ហបុរី សម្រាប់ខែវិច្ឆិកា
- ការលក់យានយន្តដឹកជញ្ជូននៅចិន សម្រាប់ខែធ្នូ